ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អាជ្ញាធរទន្លេសាប

# ផែនការសកម្មភាពការងារ

# អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ២០១៥-២០១៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរទន្លេសាប

លេខ : ០០៩/១៥ អទស

# ជម្រាបមក

## ឯកឧត្តម លោកប្រធាន និងអនុប្រធានក្តាប់រួមនាយកដ្ឋាន
## ក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

**កម្មវត្ថុ ៖** ការដាក់ឲ្យអនុវត្តន៍ផែនការសកម្មភាពការងារ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប 2015-2017 ។

**ជូនភ្ជាប់៖** ផែនការសកម្មភាពការងារ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប 2015-2017 ។

ន័យដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកប្រធាន និងអនុប្រធានក្តាប់រួម ជ្រាបថា ៖ ក្នុងស្មារតីយកចិត្តទុកដាក់ជម្រុញនូវកិច្ចការការពារធនធានធម្មជាតិ និងជីវៈចម្រុះ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ និងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ នៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធឲ្យប្រកបដោយនិរន្តរភាព ។

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានរៀបចំផែនការសកម្មភាពការងារ (2015-2017) ដើម្បីបន្តពង្រឹងការអនុវត្តបេសកកម្មស្នូលរបស់អង្គភាព ក្នុងតួនាទីសិក្សាស្រាវជ្រាវ តាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីសក្តានុពលសេដ្ឋកិច្ច សង្គមកិច្ច និងធនធានធម្មជាតិ ព្រមជាមួយនឹងតាមដាននូវរាល់សកម្មភាពបទល្មើស និងភាពអនាធិបតេយ្យនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ដើម្បីរៀបចំនូវផែនទីបង្ហាញផ្លូវ ទស្សនវិស័យ គោលនយោបាយ យុទ្ធសាស្ត្រ សម្រាប់ដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច ។

ផែនការសកម្មភាពការងារនេះ បានឆ្លុះបញ្ចាំងអំពីសកម្មភាពសំខាន់ៗ ក្នុងការចុះអនុវត្តន៍ការងារប្រមូលចងក្រងព័ត៌មាន-ទិន្នន័យ ដើម្បីចូលរួមចំណែកជួយលើកកម្ពស់ដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយចិរភាព ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកប្រធាន និងអនុប្រធានក្តាប់រួមនាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាបអនុវត្តន៍សកម្មភាពការងារខាងលើឲ្យបានល្អប្រសើរ និងមានប្រសិទ្ធភាព។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែមករា ឆ្នាំ 2015

**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**
**និងជា ប្រធានអាជ្ញាធរទន្លេសាប**

**លឹម គានហោ**

# អារម្ភកថា

បឹងទន្លេសាប គឺជាបឹងទឹកសាបធំជាងគេបំផុតក្នុងភូមិភាគអាស៊ីអាគ្នេយ៍ និងជាបេះដូងនៃប្រទេសកម្ពុជា មានតម្លៃមិនអាចកាត់ថ្លៃបាន ។ ទន្លេសាប និងបឹងទន្លេសាប គឺជាប្រព័ន្ធផ្លូវទឹកទំនាក់ទំនងយ៉ាងសំខាន់បំផុត ដែលទទួលរងនូវឥទ្ធិពលរបបទឹកពីទន្លេមេគង្គ ។ បឹងទន្លេសាប ស្រូបយកទឹកពីទន្លេមេគង្គនៅរដូវវស្សា និងបញ្ចេញទឹកទៅទន្លេមេគង្គវិញនៅរដូវប្រាំង បង្កើតបានជាបាតុភូតជលសាស្ត្រធម្មជាតិមួយកម្រមាននៅលើពិភពលោក និងបាននាំមកនូវដីល្បាប់ដ៏មានជីជាតិ ចាក់បំពេញវាលទំនាបលិចទឹកនៃតំបន់ព្រៃលិចទឹកដ៏ធំល្វឹងល្វើយ ដែលជាជម្រក និងបង្កបានជាចំណី សម្រាប់ជីវចម្រុះយ៉ាងសម្បូរបែប មានពពួកមច្ឆាជាតិ បក្សី ល្មូន ថនិកសត្វ និងរុក្ខជាតិគ្រប់ប្រភេទ ។ ក្រៅពីតួនាទីជាបឹង ដែលទទួលយកទឹក និងជួយកាត់បន្ថយគ្រោះទឹកជំនន់ពីទន្លេមេគង្គ វាក៏ជាប្រភពសន្តិសុខស្បៀង ជួយទ្រទ្រង់ដល់ជីវភាពរស់របស់ប្រជាជនកម្ពុជា និងជួយទ្រទ្រង់ដល់វិស័យសេដ្ឋកិច្ច សង្គមវប្បធម៌ និងបរិស្ថានប្រទេសជាតិទាំងមូល ។

បច្ចុប្បន្នសម្ពាធនៃការអភិវឌ្ឍន៍ និងកំណើនប្រជាពលរដ្ឋ បានធ្វើឲ្យហានិភ័យនៃបឹងទន្លេសាប បាននឹងកំពុងទទួលរងនូវការគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរ មកដល់សុខមាលភាពបឹង បរិស្ថាន ជីវចម្រុះ និងធនធានធម្មជាតិដូចជា ៖ ការប្រើប្រាស់បច្ចេកវិជ្ជាខុសបទដ្ឋានបច្ចេកទេស ការកាប់បំផ្លាញ រុករានទន្ទ្រានយកដីព្រៃលិចទឹក ការធ្វើអាជីវកម្មហួសកម្រិតលើធនធានជលផល បម្រែបម្រួលអាកាសធាតុ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការសាងសង់ទំនប់វារីអគ្គិសនី នៅផ្នែកខាងលើជាដើម ។

ដោយមើលឃើញពីសារៈសំខាន់នៃបឹងទន្លេសាប និងដើម្បីចូលរួមចំណែកក្នុងកិច្ចការការពារធនធានធម្មជាតិ និងជីវចម្រុះ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ និងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសការធានាដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានដ៏កម្រនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយនិរន្តភាព ក៏ដូចជា ការចូលរួមពង្រឹងប្រសិទ្ធភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។ **អាជ្ញាធរទន្លេសាប** បានរៀបចំនូវផែនការសកម្មភាពការងារ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប (2015-2017) បន្តពីផែនការសកម្មភាពការងារ (2014-2016) ។ ផែនការសកម្មភាពនេះ នឹងធ្វើជាឧបករណ៍បង្ហាញទិសសម្រាប់ការអនុវត្តន៍សកម្មភាពការងារប្រចាំឆ្នាំរបស់ថ្នាក់អគ្គលេខាធិការដ្ឋាន និងនាយកដ្ឋាននានាស្ថិតក្រោមឱវាទ និងជាសកម្មភាពការងារបង្ហាញជូនដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដៃគូរអភិវឌ្ឍន៍នានា ដែលមានគោលបំណងសហការ និងគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់អាជ្ញាធរទន្លេសាប ។

ផែនការសកម្មភាពការងារនេះ ចែកជា 5 ផ្នែកសំខាន់ៗគឺ ៖ ផ្នែកទី 1 បង្ហាញពីរចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់អាជ្ញាធរទន្លេសាប ដែលបង្ហាញពីបេសកកម្មរបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ។ ផ្នែកទី 2 បង្ហាញពីវឌ្ឍនភាពការអនុវត្តផែនការសកម្មភាពការងារ 2014-2016 ដែលបង្ហាញពីសមិទ្ធផល បានមកពីការអនុវត្តសកម្មភាពការងារឆ្នាំ 2014 និងបទពិសោធន៍នៃការអនុវត្តសកម្មភាពការងារកន្លងមក ។ ផ្នែកទី 3 បង្ហាញពីផែនការសកម្មភាពការងារ 2015-2017 ដែលជាទិស

ដៅការងាររបស់អគ្គលេខាធិការដ្ឋាន និងនាយកដ្ឋានក្រោមឱវាទ សម្រាប់អនុវត្ត និងសម្រេចឲ្យបាន នៅឆ្នាំ 2015 ។ ផ្នែកទី 4 បង្ហាញពីសកម្មភាពការងារប្រតិបត្តិប្រចាំឆ្នាំ 2015 ដែលជាផែនការសកម្មភាពការងារប្រចាំឆ្នាំ កំណត់នូវបណ្តាសកម្មភាពលម្អិតក្នុងទិសដៅការងារនីមួយៗ និងផ្នែកទី 5 បង្ហាញពីឧបសម្ព័ន្ធ ។

ជាមួយនឹង ផែនការសកម្មភាពការងារ 2015-2017 នេះនឹងជួយតម្រង់ទិសការងារដល់នាយកដ្ឋាននានាក្រោមឱវាទអាជ្ញាធរទន្លេសាប សម្រាប់យកទៅអនុវត្តន៍អោយមានប្រសិទ្ធភាព ហើយក៏ជាទស្សនទានសម្រាប់ជួយណែនាំដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងកៀរគដៃគូអភិវឌ្ឍន៍នានា ដែលមានគោលបំណងសហការ និងគាំទ្រទាំងផ្នែកថវិកា និងបច្ចេកទេសដល់ដំណើរការការងាររបស់អាជ្ញាធរទន្លេសាប ។

# មាតិកា

ទំព័រ

ផ្នែកទី ១៖ រចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប........................................ 1
១. លក្ខណៈទូទៅ ........................................................................................................ 1
២. រចនាសម្ព័ន្ធ និងតួនាទីភារកិច្ច ........................................................................................ 1
ផ្នែកទី ២៖វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពការងារ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប(២០១៤-២០១៦) 3
១. សេចក្តីផ្តើម ........................................................................................................ 3
២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពការងារ (២០១៤-២០១៦) ........................................ 3
២.១. សមិទ្ធផលសំខាន់ៗ ថ្នាក់អគ្គលេខាធិការដ្ឋាន ........................................................ 3
២.២. សមិទ្ធផលសំខាន់ៗ ថ្នាក់នាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ........................ 3
២.២.១ នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ........................................................ 3
២.២.២ នាយកដ្ឋានធនធានធម្មជាតិ........................................................................ 4
២.២.៣ នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស........................................................ 4
២.២.៤ នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ........................................................................ 5
៣. មេរៀន និងបទពិសោធន៍នៃការអនុវត្តផែនការសកម្មភាពការងារ (២០១៤-២០១៦)........................ 5
ផ្នែកទី ៣៖ ផែនការសកម្មភាពការងារ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប (២០១៥-២០១៧) ........................ 6
១. លក្ខណៈទូទៅ ........................................................................................................ 6
២. ទិសដៅការងារសំខាន់ៗ សម្រាប់គាំទ្រដល់ការអនុវត្តផែនការសកម្មភាព........................................ 6
២.១. ទិសដៅការងារថ្នាក់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ........................................ 6
២.២. ទិសដៅការងារថ្នាក់នាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប........................ 7
២.២.១ នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ........................................................ 7
២.២.២ នាយកដ្ឋានធនធានធម្មជាតិ........................................................................ 8
២.២.៣ នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស........................................................ 8
២.២.៤ នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ........................................................................ 9
៣. តារាងម៉ាទ្រីសផែនការសកម្មភាពការងារ (២០១៥-២០១៧)........................................................ 10
ផ្នែកទី ៤៖ សកម្មភាពការងារប្រតិបត្តិប្រចាំឆ្នាំ ២០១៥ របស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប........................ 15
១. សកម្មភាពអាទិភាពថ្នាក់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ........................................ 15
២. សកម្មភាពអាទិភាព ថ្នាក់នាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ........................ 15
២.១ នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ ........................................................ 17
២.២ នាយកដ្ឋានធនធានធម្មជាតិ........................................................................ 19
២.៣ នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ........................................................ 22
២.៤ នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ........................................................................24
៣. តារាងម៉ាទ្រីសផែនការសកម្មភាពការងារប្រតិបត្តិប្រចាំឆ្នាំ ២០១៥........................................................ 27

ផ្នែកទី ៥៖ ឧបសម្ព័ន ........................................ 47
ឧបសម្ព័ន ១ អង្គការលេខរបស់អាជ្ញាធរទន្លេសាប ........................................ 49
ឧបសម្ព័ន ២ ព្រះរាជក្រឹត្យស្តីអំពីការបង្កើតអាជ្ញាធរទន្លេសាប ........................................ 50
ឧបសម្ព័ន ៣ ព្រះរាជក្រឹត្យលេខ ០៣១០ ស្តីពីការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា១០ មាត្រា១០ មាត្រា ១២ ការបង្កើតអាជ្ញាធរទន្លេសាប ........................................ 55
ឧបសម្ព័ន ៤ អនុក្រឹត្យ ស្តីពីការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ........................................ 60
ឧបសម្ព័ន ៥ ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ ........................................ 65

# ផ្នែកទី ១
# រចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

## ១. លក្ខណៈទូទៅ

អាជ្ញាធរទន្លេសាប គឺជាអង្គភាពថ្នាក់ជាតិ និងជាសេនាធិការផ្ទាល់ឲ្យរាជរដ្ឋាភិបាល សម្រាប់សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ ដែលត្រូវបានកំណត់នៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/0609/705 ចុះថ្ងៃទី 29 ខែមិថុនា ឆ្នាំ 2009 និងបានធ្វើការកែសម្រួលទៅលើមាត្រាមួយចំនួនស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/0310/258 ចុះថ្ងៃទី 24 ខែមីនា ឆ្នាំ 2010 ស្ដីពីការកែសម្រួលមាត្រា 3 មាត្រា 5 មាត្រា 6 មាត្រា 9 មាត្រា 10 និងមាត្រា 12 នៃព្រះរាជក្រឹត្យលេខ នស/រកត/0609/705 ចុះថ្ងៃទី 29 ខែមិថុនា ឆ្នាំ 2009 ស្ដីពីការបង្កើតអាជ្ញាធរទន្លេសាប ។

ជាមួយនឹងបេសកកម្មស្នូលខាងលើ អាជ្ញាធរទន្លេសាប ក៏ជាអង្គភាពដើរតួនាទីសិក្សាស្រាវជ្រាវ តាមដាន និងវាយតម្លៃអំពីសក្ដានុពល សេដ្ឋកិច្ច សង្គមកិច្ច និងធនធានធម្មជាតិនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ដើម្បីរៀបចំឡើងនូវផែនទីបង្ហាញផ្លូវ (ផែនការមេ) ទស្សនវិស័យ គោលនយោបាយ យុទ្ធសាស្ត្រ សម្រាប់ដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច ។ម្យ៉ាងវិញទៀត អាជ្ញាធរទន្លេសាប ក៏អាចនឹងក្លាយទៅជាអង្គភាព ដើរតួនាទីជាប្រតិបត្តិករ នៅពេលដែលទទួលបាននូវបទបញ្ជាផ្ទាល់ពីរាជរដ្ឋាភិបាល ។

ជាសរុប ការបង្កើតឡើងអាជ្ញាធរទន្លេសាប មានគោលបំណងដូចខាងក្រោម ៖

- សេនាធិការឲ្យរាជរដ្ឋាភិបាល
- លើកកម្ពស់កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ដែលជាទិសដៅអាទិភាព ដើម្បីលើកកម្ពស់សុខមាលភាពសង្គម និងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- លើកកម្ពស់កិច្ចការការពារ និងថែរក្សាធនធានធម្មជាតិ និងបរិស្ថាន ដែលជាទិសដៅអាទិភាព ដើម្បីធានាដល់គុណភាពធនធានធម្មជាតិ និងបរិស្ថាន
- ជាអង្គភាពសម្របសម្រួលរាល់គម្រោង ដែលបាន និងកំពុងតែអនុវត្តនៅតំបន់ជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ។

## ២. រចនាសម្ព័ន្ធ និងតួនាទីភារកិច្ច

រចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ត្រូវបានកំណត់នៅក្នុងអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ 116 អនក្របក ចុះថ្ងៃទី 30 ខែកក្កដា ឆ្នាំ 2009 សម្រាប់ដំណើរការងារប្រចាំថ្ងៃ និងចាត់ការទូទៅលើការងារសម្របសម្រួល ទំនាក់ទំនង និងសហការរវាងក្រសួង ស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា សម្រាប់គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាបប្រកបដោយនិរន្តរភាព ។ ផ្អែកតាមអនុក្រឹត្យនេះ អគ្គលេខាធិការដ្ឋានមាននាយកដ្ឋានក្រោមឱវាទចំនួន 04 និងការិយាល័យចំនួន 14 មានដូចខាងក្រោម ៖

- នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ — ការិយាល័យចំនួន 04
- នាយកដ្ឋានធនធានធម្មជាតិ — ការិយាល័យចំនួន 04
- នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស — ការិយាល័យចំនួន 03

❖ នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ការិយាល័យចំនួន 03

ផែនការសកម្មភាពការងារ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប (2015-2017) នឹងឆ្លុះបញ្ចាំងឲ្យឃើញពីទិសដៅការងារ និងសកម្មភាពការងារអាទិភាពប្រចាំឆ្នាំ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប និងនាយកដ្ឋានក្រោមឱវាទ ដែលស្របតាមតួនាទីភារកិច្ច បានកំណត់ក្នុងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងាររបស់អាជ្ញាធរទន្លេសាប សម្រេចឲ្យបានជោគជ័យ ប្រកបដោយចិរភាពក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ ។

# ផ្នែកទី ២

## វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពការងារ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប (២០១៤-២០១៦)

### ១. សេចក្តីផ្តើម

ផែនការសកម្មភាពការងារ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប 2014-2016 គឺជាផែនការសកម្មភាពលើកទី 1 ដែលត្រូវបានរៀបចំឡើង ដើម្បីចូលរួមចំណែកការអនុវត្តន៍នូវគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា។ ជាក់ស្តែង ផែនការសកម្មភាព នេះត្រូវបានរៀបចំឡើង ដោយបានកំណត់នូវសកម្មភាពការងារអាទិភាពរបស់នាយកដ្ឋានក្រោមឱវាទ ដើម្បីអនុវត្តសម្រេចឲ្យបាននូវគោលបំណង លទ្ធផល (Outcome) និងធាតុចេញ (Output) រួមរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដែលត្រូវបានប្រើប្រាស់នូវកញ្ចប់ថវិកាជាតិប្រចាំឆ្នាំរបស់អាជ្ញាធរ ទន្លេសាប ។

ជាមួយនឹងនេះដែរ ក្នុងចំណោមសកម្មភាពការងារ ដែលបានកំណត់នៅក្នុងផែនការសកម្មភាពអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ក៏សកម្មភាពមួយចំនួន មិនត្រូវបានអនុវត្តពេញលេញ ដោយមូលហេតុខ្វះខាតថវិកា សម្រាប់ដំណើរការអនុវត្តន៍ ។ វឌ្ឍនភាពនៃការអនុវត្តន៍ផែនការសកម្មភាពការងារ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដូចមានរៀបរាប់ខាងក្រោម ។

### ២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពការងារ (២០១៤-២០១៦)

### ២.១. សមិទ្ធផលសំខាន់ៗ ថ្នាក់អគ្គលេខាធិការដ្ឋាន

បន្ទាប់ពីការៀបចំផែនការសកម្មភាពការងារ អគ្គលេខាធិការដ្ឋាន 2014-2016 ត្រូវបានបញ្ចប់ និងទទួលបានការអនុម័តពីឯកឧត្តប្រធាន អាជ្ញាធរទន្លេសាប ។ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានរៀបចំធ្វើការផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ន និងនាយកដ្ឋានពាក់ព័ន្ធ ដើម្បីរួមសហការ និងអនុវត្តឲ្យមានប្រសិទ្ធភាព ។ ជាមួយនឹងសកម្មភាពការងារដែលមាននៅក្នុងផែនការសកម្មភាពការងារ គឺមានសកម្មភាពការងារមួយចំនួន មិនបានកំណត់នៅក្នុងផែនការសកម្មភាពការងារ ត្រូវបានថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បាននឹងកំពុងតែអនុវត្ត ដើម្បីសម្រេចឲ្យបាននូវគោលបំណងរួមរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប ។

- ✓ ការចុះអនុវត្តការងារអធិការកិច្ច វិនាសកម្មព្រៃលិចទឹកតំបន់ជុំវិញបឹងទន្លេសាប
- ✓ ការចុះតាមដានត្រួតពិនិត្យភាពអនាធិបតេយ្យ និងបទល្មើសក្នុងការធ្វើអាជីវកម្មភាពហួសហេតុ និងខុសច្បាស់មកលើធនធានធម្មជាតិ និងធនធានជលផល
- ✓ ការតាមដាន និងវាយតម្លៃពីផលស្តុកធនធានជលផល
- ✓ ការតាមដាន និងវាយតម្លៃពីការធ្វើអាជីវកម្មកែច្នៃប្រហុក និងសិប្បកម្មនានា
- ✓ ការចូលរួមត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី 3 របស់រាជរដ្ឋាភិបាល
- ✓ ការបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និងដៃគូរពាក់ព័ន្ធនានា

### ២.២. សមិទ្ធផលសំខាន់ៗ ថ្នាក់នាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប

### ២.២.១. នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ

- ✓ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលក្នុងអាជ្ញាធរទន្លេសាប ត្រូវបានពង្រឹង និងមានដំណើរការល្អប្រសើរ
- ✓ រាល់លិខិត បទដ្ឋានគតិយុត្តិ និងឯកសារពាក់ព័ន្ធ ត្រូវបានរៀបចំ និងចាត់ចែងបានត្រឹមត្រូវ

- ✓ ការប្រតិបត្តិគណនេយ្យនិងហិរញ្ញវត្ថុក្នុងអាជ្ញាធរទន្លេសាប ត្រូវបានពង្រឹង និងមានលក្ខណៈល្អប្រសើរ
- ✓ រាល់ការទូទាត់ និងការចំណាយរបស់អាជ្ញាធរទន្លេសាប ត្រូវបានដោះស្រាយទាន់ពេលវេលា
- ✓ រាល់តម្រូវការរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ត្រូវបានសម្របសម្រួល និងយកចិត្តទុកដាក់ខ្ពស់
- ✓ ការគ្រប់គ្រងមន្ត្រីរាជការរបស់អាជ្ញាធរទន្លេសាប ត្រូវបានយកចិត្តទុកដាក់ និងលើកទឹកចិត្ត តាមរយៈនៃរៀបចំតាមប្រព័ន្ធ Electronic តំឡើងឋានន្តរស័ក្តិ និងតួនាទី និងចាត់ចែងឯកសារពាក់ព័ន្ធ
- ✓ មន្ត្រីជំនាញអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ត្រូវបានផ្តល់ឱកាស និងលើកកម្ពស់សមត្ថភាព
- ✓ ផែនការសកម្មភាពការងារ ផែនការថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរទន្លេសាប ត្រូវបានបញ្ជ្រាបក្នុងផែនការប្រចាំឆ្នាំរបស់ក្រសួងធនធានទឹក និងឧតុនិយម
- ✓ គម្រោងអាទិភាពមួយចំនួនរបស់អាជ្ញាធរទន្លេសាប ត្រូវបានបញ្ចូលក្នុងកម្មវិធីវិនិយោគសាធារណៈ (ក្រសួងផែនការ) និងផែនការថ្នាក់តំបន់ (MRCs and CNMC) ដើម្បីស្វែងរកការគាំទ្រ
- ✓ រាល់សកម្មភាពអនុវត្តការងាររបស់នាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាន ត្រូវបានធ្វើការបូកសរុប និងតាមដានពីវឌ្ឍនភាពនៃការអនុវត្តការងារ សម្រាប់ការរីកចម្រើនរបស់អាជ្ញាធរទន្លេសាប
- ✓ រាល់គម្រោង បាន និងកំពុងអនុវត្តក្នុងតំបន់បឹងទន្លេសាប ត្រូវបានប្រមូលផ្តុំ និងចងក្រង
- ✓ កិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួង ស្ថាប័ន និងដៃគូរពាក់ព័ន្ធ បាន និងកំពុងតែពង្រឹង

### ២.២.២. នាយកដ្ឋានធនធានធម្មជាតិ

- ✓ ព័ត៌មាន ទិន្នន័យផ្ទៃដីដាំដុះដំណាំកសិកម្មក្នុងតំបន់សំខាន់មួយចំនួនជុំវិញបឹងទន្លេសាប ត្រូវបានបច្ចុប្បន្នភាព និងរៀបចំផែនទី សម្រាប់សិក្សា និងវិភាគ
- ✓ ព័ត៌មាន ទិន្នន័យផ្នែកសេដ្ឋកិច្ច សង្គមកិច្ច លើវិស័យកសិកម្ម ក្នុងតំបន់មួយចំនួនជុំវិញបឹងទន្លេសាប ត្រូវបានប្រមូល និងចងក្រង សម្រាប់សិក្សា និងវិភាគ
- ✓ ព័ត៌មាន ទិន្នន័យអំពីប្រភេទស្រូវដាំដុះក្នុងតំបន់ជុំវិញបឹងទន្លេសាប ត្រូវបានប្រមូលចងក្រង សម្រាប់សិក្សា និងវិភាគ
- ✓ ព័ត៌មាន ទិន្នន័យអំពីលទ្ធភាពនៃការស្រោចស្រព និងប្រភពទឹកសំខាន់ៗជុំវិញបឹងទន្លេសាប ត្រូវបានប្រមូលចងក្រង និងរៀបចំផែនទី សម្រាប់សិក្សា និងវិភាគ
- ✓ ព័ត៌មាន ទិន្នន័យអំពីប្រភេទព្រៃលិចទឹក ក្នុងតំបន់សំខាន់ៗមួយចំនួនជុំវិញបឹងទន្លេសាប ត្រូវបានចុះបច្ចុប្បន្នភាព និងរៀបចំផែនទី សម្រាប់សិក្សា និងវិភាគ
- ✓ ព័ត៌មាន ទិន្នន័យជីវសាស្ត្រត្រី វារីរុក្ខជាតិ វារីសត្វទឹក និងសបីសត្វ នៃជីវៈចម្រុះក្នុងតំបន់សំខាន់ៗក្នុងតំបន់បឹងទន្លេសាប ត្រូវបានចុះសិក្សា និងប្រមូលចងក្រង សម្រាប់វិភាគ

រាល់លទ្ធផលព័ត៌មាន ទិន្នន័យ ដែលបានមកពីការចុះសិក្សាស្រាវជ្រាវ មន្ត្រីបច្ចេកទេស នាយកដ្ឋានធនធានធម្មជាតិ បាននឹងកំពុងតែធ្វើការពិនិត្យ និងវិភាគដើម្បីរៀបចំចងក្រងសៀវភៅបច្ចេកទេសសម្រាប់ទុកជាលទ្ធផលរបកគំហើញនៃការសិក្សាស្រាវជ្រាវ និងរៀបចំផែនការអនុវត្តនៅជំហានបន្តបន្ទាប់ ។

### ២.២.៣. នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស

- ✓ ព័ត៌មាន ទិន្នន័យពីផលស្តុកត្រី ត្រូវបានធ្វើបច្ចុប្បន្នភាព តាមរយៈនៃការចុះសិក្សា និងវាយតម្លៃ លើផលចាប់តាមឡូត៍ដាយ និងប្រជានេសាទ (ធនធានជលផលថយចុះ ត្រីលេខ 1 និងលេខ 2 មានការខ្សត់ខ្សោយ)
- ✓ ការចុះតាមដានពីចរាចរត្រីចេញពីទន្លេសាប ទៅទន្លេមេគង្គលើ ទន្លេមេគង្គក្រោម និងទន្លេបាសាក់

- ✓ ព័ត៌មាន ទិន្នន័យភូមិសាស្ត្រ នៃតំបន់ដែនសហគមន៍នេសាទ តំបន់កែច្នៃ តំបន់អភិរក្សជលផល ត្រូវបានប្រមូលរៀបចំជាផែនទី សម្រាប់ការសិក្សា និងវិភាគ
- ✓ ព័ត៌មាន ទិន្នន័យភូមិសាស្ត្រអំពីយឿត្រី ស្ថានភាពបាតទន្លេ ជម្រៅទឹក និងចរន្តទឹក ត្រូវបានរៀបចំជាផែនទី សម្រាប់ការសិក្សា និងវិភាគ
- ✓ ព័ត៌មាន ទិន្នន័យតំបន់អភិរក្សជលផល ត្រូវបានប្រមូល និងចងក្រង សម្រាប់ការសិក្សា និងវិភាគ
- ✓ ព័ត៌មាន ទិន្នន័យសហគមន៍នេសាទជុំវិញបឹងទន្លេសាប ត្រូវបានប្រមូលផ្តុំ និងចងក្រង សម្រាប់ការសិក្សា និងវិភាគ
- ✓ ព័ត៌មាន ទិន្នន័យការធ្វើអាជីវកម្មកែច្នៃ ត្រូវបានប្រមូលផ្តុំ និងចងក្រង សម្រាប់ការសិក្សា និងវិភាគ (បរិមាណកែច្នៃថយចុះ តម្លៃត្រីកើនឡើង)

រាល់លទ្ធផលព័ត៌មាន ទិន្នន័យ ដែលបានមកពីការចុះសិក្សាស្រាវជ្រាវ មន្ត្រីបច្ចេកទេស នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស បាននឹងកំពុងតែធ្វើការពិនិត្យ និងវិភាគដើម្បីរៀបចំចងក្រងសៀវភៅបច្ចេកទេសសម្រាប់ទុកជាលទ្ធផលរបកគំហើញនៃការសិក្សាស្រាវជ្រាវ និងរៀបចំផែនការអនុវត្តនៅជំហានបន្តបន្ទាប់ ។

**២.២.៤. នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ**

- ✓ ប្រព័ន្ធព័ត៌មាន និង Website របស់អាជ្ញាធរទន្លេសាប ត្រូវបានបច្ចុប្បន្នភាពកាន់តែប្រសើរ
- ✓ បណ្ណាល័យសិក្សាស្រាវជ្រាវក្នុងអាជ្ញាធរទន្លេសាប បាន និងកំពុងដំណើរការ
- ✓ ទស្សនាវដ្តីអំពីសកម្មភាពអនុវត្តការងាររបស់អាជ្ញាធរទន្លេសាប និងប័ណ្ណជូនពរ ត្រូវបានចងក្រង និងបោះពុម្ពផ្សព្វផ្សាយ
- ✓ ឯកសារស្រាវជ្រាវទាំងផ្នែកបច្ចេកទេស និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ត្រូវបានប្រមូលផ្តុំ និងចងក្រងក្នុងបណ្ណាល័យ
- ✓ ព័ត៌មាន ទិន្នន័យនៃការអនុវត្តច្បាប់ និងនីតិវិធីដោះស្រាយវិវាទក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានតំបន់ទន្លេសាប ត្រូវបានចុះសិក្សា ដើម្បីធ្វើការវិភាគពីភាពខ្លាំង និងខ្សោយ

រាល់លទ្ធផលព័ត៌មាន ទិន្នន័យ ដែលបានមកពីការចុះសិក្សាស្រាវជ្រាវ មន្ត្រីបច្ចេកទេស នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ បាននឹងកំពុងតែធ្វើការពិនិត្យ និងវិភាគដើម្បីរៀបចំចងក្រងសៀវភៅបច្ចេកទេសសម្រាប់ទុកជាលទ្ធផលរបកគំហើញនៃការសិក្សាស្រាវជ្រាវ និងរៀបចំផែនការអនុវត្តនៅជំហានបន្តបន្ទាប់ ។

**៣. មេរៀន និងបទពិសោធន៍នៃការអនុវត្តផែនការសកម្មភាពការងារ (២០១៤-២០១៦)**

ឆ្លងតាមការត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តផែនការសកម្មភាពការងារ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាបនៅលើកទី 1 (2014-2016) បានឆ្លុះបញ្ចាំងឲ្យឃើញពីបញ្ហាធំៗមួយចំនួន ដែលជាបញ្ហាប្រឈមនឹងដំណើរការអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋាននីមួយៗ និងមិនអាចសម្រេចបានជោគជ័យទាំងទៅតាមសកម្មភាពការងារ ដែលបានលើកឡើងក្នុងផែនការសកម្មភាពការងារប្រចាំឆ្នាំ ។ បញ្ហាប្រឈមទាំងនោះរួមមាន ៖

- ✓ សមត្ថភាពចំណេះដឹង និងបទពិសោធន៍ការងាររបស់មន្ត្រីរដ្ឋបាល និងបច្ចេកទេស នៅមានកម្រិតទាំងការទទួលខុសត្រូវ និងការអនុវត្តការងារ
- ✓ សម្ភារៈបច្ចេកទេស សម្រាប់ឲ្យមន្ត្រីចុះអនុវត្តការងារ នៅមានការខ្វះខាត
- ✓ កញ្ចប់ថវិកាសម្រាប់ចុះអនុវត្តការងារ នៅមានកម្រឹត និងមានភាពយឺតយ៉ាវ ក្នុងការដោះស្រាយ

- ✓ ការផ្តល់កិច្ចសហប្រតិបត្តិការ របស់មន្ត្រីជលផល អាជ្ញាធរដែនដី និងមន្ត្រីក្រសួង ស្ថាប័នពាក់ជាមួយនឹងមន្ត្រីស្រាវជ្រាវរបស់អាជ្ញាធរទន្លេសាប មិនទាន់មានភាពរលូន ដោយសារការបាត់បង់ផលប្រយោជន៍ពីឈ្មួញ
- ✓ សកម្មភាពការងារដែលបានលើកឡើងមានច្រើន ដោយកត្តាធនធានមនុស្ស ថវិកា និងពេលវេលា គឺមិនអាចសម្រេចបានមួយរយភាគរយតាមផែនការនោះទេ ។

# ផ្នែកទី ៣

## ផែនការសកម្មភាពការងារ អគ្គលេខាធិការដ្ឋាន

## នៃអាជ្ញាធរទន្លេសាប (២០១៥-២០១៧)

**១. លក្ខណៈទូទៅ**

ផែនការសកម្មភាព អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប 2015-2017 គឺជាផែនការសកម្មភាពលើកទី 2 ដែលត្រូវបានធ្វើបច្ចុប្បន្នភាពលើផែនការសកម្មភាពលើកទី 1 មានអាណត្តិចាប់ពីឆ្នាំ 2014-2016 ក្នុងការការចូលរួមលើកកម្ពស់ប្រសិទ្ធភាពការងាររបស់អាជ្ញាធរទន្លេសាប ដើម្បីបន្តរួមចំណែកអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងដើម្បីធ្វើជាឧបករណ៍ សម្រាប់តម្រង់ទិសការគាំទ្រដល់ការប្រើប្រាស់កញ្ចប់ថវិកាជាតិ និងដៃគូអភិវឌ្ឍន៍ទាំងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ ។ ផែនការសកម្មភាព អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ត្រូវបានរៀបចំឡើងដោយមានការចូលរួមពីមន្ត្រីបច្ចេកទេសថ្នាក់អគ្គលេខាធិការដ្ឋាន និងនាយកដ្ឋានក្រោមឱវាទ ដោយបានបង្ហាញពីសកម្មភាពសម្រាប់អនុវត្តការងារប្រចាំឆ្នាំ ។

ផែនការសកម្មភាព អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប 2015-2017 នឹងបង្ហាញពីទិសដៅការងារសំខាន់ៗ សម្រាប់អនុវត្តនៅក្នុងអំឡុងពេលនៃផែនការសកម្មភាព 2015-2017 រួមជាមួយនឹងសកម្មភាពលម្អិតក្នុងទិសដៅការងារនីមួយៗ(តារាងម៉ាទ្រីសទី1)ទាំងថ្នាក់អគ្គលេខាធិការដ្ឋាន និងថ្នាក់នាយកដ្ឋានក្រោមឱវាទ ។

**២. ទិសដៅការងារសំខាន់ៗ សម្រាប់គាំទ្រដល់ការអនុវត្តផែនការសកម្មភាព**

**២.១. ទិសដៅការងារថ្នាក់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប**

នៅក្នុងផែនការសកម្មភាពនេះ ថ្នាក់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានលើកឡើងនូវទិសដៅការងារសំខាន់ៗចំនួន 02 ដើម្បីអនុវត្តពីឆ្នាំ 2015-2017 នៅក្នុងទិសដៅការងារនីមួយៗ មានសកម្មភាពការងារច្រើន ដែលត្រូវអនុវត្តក្នុងអំឡុងពេលនៃផែនការនេះ ។

**ទិសដៅការងារទី ១ ៖** បន្តការចូលរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការចាត់វិធានការ និងការការពារតំបន់ជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព

**ផែនការសកម្មភាព ១.១.** អធិការកិច្ចព្រៃលិចទឹកតំបន់ 3 ជុំវិញបឹងទន្លេសាប

១.១.១. ចុះពិនិត្យ និងតាមដាន អំពីការបាត់បង់ព្រៃលិចទឹក

១.១.២. ចុះពិនិត្យ និងតាមដានបង្គោលកំណត់តំបន់ 3 ជុំវិញបឹងទន្លេសាប

១.១.៣. រៀបចំរបាយការណ៍/ខ្លឹមសារគោលនយោបាយ (Policy Brief)

**ផែនការសកម្មភាព ១.២.** សិក្សា និងវាយតម្លៃភាពអនាធិបតេយ្យ និងបទល្មើស ជុំវិញបឹងទន្លេសាប

១.២.១. ចុះពិនិត្យ និងតាមដានពីស្ថានភាពអនាធិបតេយ្យ និងបទល្មើស

១.២.២. សម្របសម្រួល និងសហការក្នុងការទប់ស្កាត់ភាពអនាធិបតេយ្យ និងបទល្មើស

១.២.៣. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**ទិសដៅការងារទី ២ ៖** លើកកម្ពស់ប្រសិទ្ធិភាពការងារ និងសម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ

**ផែនការសកម្មភាព ២.១.** សិក្សា និងវាយតម្លៃអំពីតំបន់ដីសើមជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

២.១.១. សម្របសម្រួល ការប្រមូលចងក្រងព័ត៌មានទិន្នន័យតំបន់ដីសើមដែលមានស្រាប់

២.១.២. សិក្សាប្រមូលព័ត៌មាន ទិន្នន័យតំបន់ដីសើមជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

២.១.៣. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**ផែនការសកម្មភាព ២.២.** សិក្សា និងវាយតម្លៃពីការគ្រប់គ្រងកាកសំណល់ភូមិបណ្តែតទឹក ក្នុងតំបន់បឹងទន្លេសាប

២.២.១. សម្របសម្រួល និងធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យភូមិបណ្តែតទឹក ជាមួយនឹងអ្នកពាក់ព័ន្ធ

២.២.៣. ចុះសិក្សា និងប្រមូលព័ត៌មាន ទិន្នន័យការប្រើប្រាស់កាកសំណល់រឹង និងរាវ

២.២.៤. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**ផែនការសកម្មភាព ២.៣.** សិក្សា និងវាយតម្លៃពីការបង្កបង្កើនផលដំណាំកសិកម្មតំបន់ជុំវិញបឹងទន្លេសាប

២.៣.១. សិក្សាស្រាវជ្រាវចរន្តទីផ្សារកសិផល នៃសង្វាក់ដំណាំស្រូវវស្សា និងស្រូវប្រាំង

២.៣.២. ចុះសិក្សា និងប្រមូលព័ត៌មានទិន្នន័យពីការបង្កបង្កើនផលស្រូវប្រាំង និងវស្សា

២.៣.៣. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**ផែនការសកម្មភាព ២.៤.** សិក្សាស្រាវជ្រាវពីសង្វាក់អាជីវកម្មកែច្នៃធនធានជលផល

២.៤.១. តាមដាន និងវាយតម្លៃពីសង្វាក់ផលិតកម្ម និងសិប្បកម្មកែច្នៃធនធានជលផល

២.៤.២. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**ផែនការសកម្មភាព ២.៥.** សិក្សា និងវាយតម្លៃពីផលិតភាពធនធានជលផលនៅក្នុងបឹងទន្លេសាប

២.៥.១. តាមដាន និងវាយតម្លៃពីលិតភាពធនធានជលផលនៅក្នុងបឹងទន្លេសាប

២.៥.២. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**២.២. ទិសដៅការងារថ្នាក់នាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប**

ជាមួយនឹងឯកសារផែនការសកម្មភាពនេះដែរ ថ្នាក់នាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានលើកឡើងនូវទិសដៅការងារសំខាន់ៗចំនួន 4 ដើម្បីអនុវត្តពីឆ្នាំ 2015-2017 នៅក្នុងទិសដៅការងារនីមួយៗនៃផែនការសកម្មភាព ក៏មានសកម្មភាពការងារច្រើន ដែលត្រូវអនុវត្តក្នុងអំឡុងពេលនៃផែនការនេះ ។

**២.២.១. នាយដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ**

**ទិសដៅការងារទី ៣ ៖** អភិបាលកិច្ចការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិក ក្នុងកិច្ចសហប្រតិបត្តិការ ដើម្បីលើកកម្ពស់ប្រសិទ្ធិភាពការងារសម្រាប់អាជ្ញាធរទន្លេសាប

**ផែនការសកម្មភាព ៣.១.** សម្របសម្រួល និងធ្វើឲ្យកាន់តែប្រសើរឡើងនូវដំណើរការគ្រប់គ្រងប្រព័ន្ធរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិក ក្នុងអង្គភាពអាជ្ញាធរទន្លេសាប

៣.១.១. បន្តពង្រឹងការគ្រប់គ្រងផ្នែករដ្ឋបាល

៣.១.២. បង្កើនការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ

៣.១.៣. ជម្រុញប្រសិទ្ធភាពការគ្រប់គ្រងបុគ្គលិក-មន្ត្រីរាជការ

៣.១.៤. បន្តការលើកកម្ពស់ការកសាងសមត្ថភាព

៣.១.៥. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**ផែនការសកម្មភាព ៣.២.** ពង្រឹងប្រសិទ្ធភាពដំណើរការអនុវត្តផែនការ និងកិច្ចសហប្រតិបត្តិការ

៣.២.១. បន្តការយកចិត្តទុកដាក់នូវយន្តការរៀបចំផែនការ

៣.២.២. គ្រប់គ្រងព័ត៌មាន ទិន្នន័យរបស់អាជ្ញាធរទន្លេសាប

៣.២.៣. បន្តពង្រឹងកិច្ចសហប្រតិបត្តិការ

៣.២.៤. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**២.២.២. នាយកដ្ឋានធនធានធម្មជាតិ**

**ទិសដៅការងារទី ៤ ៖** សម្របសម្រួល និងធ្វើឲ្យព័ត៌មាន ទិន្នន័យធនធានធម្មជាតិនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធកាន់តែប្រសើរឡើង

**ផែនការសកម្មភាព ៤.១. បច្ចុប្បន្នភាពព័ត៌មាន ទិន្នន័យសក្តានុពលធនធានធម្មជាតិ តំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ**

៤.១.១. សិក្សាស្រាវជ្រាវពីប្រភេទព្រៃលិចទឹក និងរុក្ខជាតិផ្សេងៗតំបន់ជុំវិញបឹងទន្លេសាប

៤.១.២. សិក្សាស្រាវជ្រាវពីសុខមាលភាពបឹង ស្ទឹង តាមតំបន់សំខាន់ៗជុំវិញបឹងទន្លេសាប

៤.១.៣. សិក្សាស្រាវជ្រាវពីគុណភាពដីកសិកម្មក្នុងតំបន់សំខាន់ៗជុំវិញបឹងទន្លេសាប

៤.១.៤. សិក្សាស្រាវជ្រាវពីធនធានរ៉ែក្នុងតំបន់សំខាន់ជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

៤.១.៥. សិក្សាស្រាវជ្រាវពីជីវចម្រុះ តំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

៤.១.៦. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**ផែនការសកម្មភាព ៤.២.** សិក្សាស្រាវជ្រាវពីការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធអេកូឡូស៊ីជុំវិញបឹងទន្លេសាប

៤.២.១. បច្ចុប្បន្នភាពព័ត៌មាន ទិន្នន័យប្រព័ន្ធស្រោចស្រពស្ទឹងសំខាន់ៗ និងអាងស្រែជុំវិញបឹងទន្លេសាប

៤.២.២. សិក្សាស្រាវជ្រាវពីសក្តានុពលសេដ្ឋកិច្ច លើការបង្កបង្កើនផលដំណាំចំការជុំវិញតំបន់បឹងទន្លេសាប

៤.២.៣. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**២.២.៣. នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស**

**ទិសដៅការងារទី ៥ ៖** សម្របសម្រួល និងធ្វើឲ្យប្រសើរឡើងនូវការស្រង់ព័ត៌មាន ទិន្នន័យ នៃការធ្វើអាជីវកម្ម និងអភិរក្សធនធាននៅតំបន់បឹងទន្លេសាប និង តំបន់ពាក់ព័ន្ធ

**ផែនការសកម្មភាព ៥.១.** បន្តធ្វើបច្ចុប្បន្នភាពព័ត៌មានទិន្នន័យ ការធ្វើអាជីវកម្មធនធាន នៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

៥.១.១. សិក្សា និងវាយតម្លៃផលចាប់តាមឡូត៍ដាយ នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល ២០១៥-២០១៦

៥.១.២. សិក្សាពីសង្វាក់ការធ្វើអាជីវកម្មលើធនធានជីវចម្រុះ ជុំវិញបឹងទន្លេសាប

៥.១.៣. តាមដានសង្វាក់ពាណិជ្ជកម្មច្រកចេញ-ចូលត្រី បណ្តាខេត្តជុំវិញបឹងទន្លេសាប

៥.១.៤. សិក្សាវាយតម្លៃធនធានជលផលតាមស្ទឹងសំខាន់ៗជុំវិញបឹងទន្លេសាប

៥.១.៥. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**ផែនការសកម្មភាព ៥.២.** ធ្វើឲ្យប្រសើរឡើងនូវព័ត៌មាន ទិន្នន័យនៃការប្រើប្រាស់ឧបករណ៍នេសាទ និងតំបន់អភិរក្សធនធានជលផល ស្ថិតជុំវិញបឹងទន្លេសាប

៥.២.១. ធ្វើបច្ចុប្បន្នភាពឧបករណ៍នេសាទនៅបណ្តាខេត្តជុំវិញបឹងទន្លេសាប

៥.២.២. ធ្វើបញ្ជីសារពើភ័ណ្ឌតំបន់អភិរក្សជលផល នៅតាមបណ្ដាខេត្តជុំវិញបឹងទន្លេសាប

៥.២.៣. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**២.២.៤. នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ**

**ទិសដៅការងារទី ៦ ៖** ពង្រឹងប្រសិទ្ធភាពការអនុវត្តបទដ្ឋានគតិយុត្តិ និងធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធផ្សព្វផ្សាយ ក្នុងស្មារតីលើកកម្ពស់ដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ និងជីវចម្រុះតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

**ផែនការសកម្មភាព ៦.១.** បន្តការចូលរួមលើកកម្ពស់ការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តិ ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ និងជីវចម្រុះតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

៦.១.១. ពង្រឹងការអនុវត្តបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការការពារតំបន់ជុំវិញបឹងទន្លេសាប

៦.១.២. សិក្សាស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងកិច្ចការការពារធនធានធម្មជាតិ និងជីវចម្រុះតំបន់បឹងទន្លេសាប

៦.១.៣. សិក្សាស្វែងយល់ពីការចែករំលែកអត្ថប្រយោជន៍ (Conflict Interest) រវាងអ្នកពាក់ព័ន្ធ ក្នុងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់បឹងទន្លេសាបប្រកបដោយនិរន្តរភាព

៦.១.៤. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**ផែនការសកម្មភាព ៦.២.** បង្កើនការយល់ដឹងឲ្យបានទូលំទូលាយ សំដៅបម្រើឲ្យកិច្ចអភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព និងនិរន្តភាព

៦.២.១. បច្ចុប្បន្នភាពប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានជាសាធារណៈ

៦.២.២. បញ្ជ្រាបការយល់ដឹងជាសាធារណៈ អំពីកិច្ចការពារធនធានធម្មជាតិ និងជីវចម្រុះបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

៣. តារាងម៉ាទ្រីសផែនការសកម្មភាពការងារ (២០១៥-២០១៧)

# តារាងម៉ាទ្រីសសកម្មភាពប្រតិបត្តការងារឆ្នាំ ២០១៥-២០១៧

| ទិសដៅការងារ | ផែនការសកម្មភាព | ពេលវេលាសម្រាប់អនុវត្ត | | | តម្រូវការគាំទ្រ |
|---|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ | តម្លៃប៉ាន់ស្មាន |
| **អគ្គលេខាធិការដ្ឋាន** | | √ | √ | √ | 6144,723,000 |
| **ទិសដៅទី ១** បន្តការចូលរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការចាត់វិធានការ និងការការពារតំបន់ជុំវិញបឹងទន្លេសាបនិងតំបន់ពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព | ១.១. អធិការកិច្ចព្រៃលិចទឹកតំបន់ 3 ជុំវិញបឹងទន្លេសាប | √ | √ | √ | 1985,000,000 |
| | ១.១.១. ចុះពិនិត្យ និងស្រង់ព័ត៌មាន-ទិន្នន័យ អំពីការបាត់បង់ព្រៃលិចទឹក | √ | √ | √ | 90,400,000 |
| | ១.១.២. ចុះពិនិត្យ និងការពារបង្គោលកំណត់តំបន់ 3 ជុំវិញបឹងទន្លេសាប | √ | √ | √ | 1887,600,000 |
| | ១.១.៣. រៀបចំរបាយការណ៍/ឯកសារពិសេសជូនថ្នាក់ដឹកនាំ និងរាជរដ្ឋាភិបាល) | √ | √ | √ | 7,000,000 |
| | ១.២. សិក្សា និងវាយតម្លៃភាពអនាធិបតេយ្យ និងបទល្មើស ជុំវិញបឹងទន្លេសាប | √ | √ | √ | 680,000,000 |
| | ១.២.១. ចុះពិនិត្យ និងតាមដានពីភាពស្ថានភាពអនាធិបតេយ្យ និងបទល្មើស | √ | √ | √ | 580,000,000 |
| | ១.២.២. សម្របសម្រួល និងសហការក្នុងការទប់ស្កាត់ភាពអនាធិបតេយ្យ និងបទល្មើស | √ | √ | √ | 70,000,000 |
| | ១.២.៣. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief) | √ | √ | √ | 30,000,000 |
| **ទិសដៅទី ២** លើកកម្ពស់ប្រសិទ្ធិភាពការងារ និងសម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ | ២.១. សិក្សា និងវាយតម្លៃអំពីតំបន់ដីសើមជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ | √ | √ | √ | 446,000,000 |
| | ២.១.១. សម្របសម្រួល ការប្រមូលចងក្រងព័ត៌មានទិន្នន័យតំបន់ដីសើមដែលមានស្រាប់ | √ | √ | | 214,000,000 |
| | ២.១.២. សិក្សាប្រមូលព័ត៌មាន ទិន្នន័យតំបន់ដីសើមជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ | √ | √ | √ | 226,000,000 |
| | ២.១.៣. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief) | √ | √ | √ | 6,000,000 |
| | ២.២. សិក្សា និងវាយតម្លៃពីការគ្រប់គ្រងកាកសំណល់ភូមិបណ្តែតទឹក ក្នុងតំបន់បឹងទន្លេសាប | √ | √ | √ | 458,000,000 |

| | | | | | |
|---|---|---|---|---|---|
| ទន្លេសាប និងតំបន់ពាក់ព័ន្ធ | ២.២.១. សម្របសម្រួល និងធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យភូមិបណ្ដែតទឹក ជាមួយនឹងអ្នកពាក់ព័ន្ធ | √ | √ | | 192,000,000 |
| | ២.២.២. ចុះសិក្សា និងប្រមូលព័ត៌មាន ទិន្នន័យការប្រើប្រាស់កាកសំណល់រឹង និងរាវ | √ | √ | √ | 260,000,000 |
| | ២.២.៣. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief) | √ | √ | √ | 6,000,000 |
| | ២.៣. សិក្សា និងវាយតម្លៃពីការបង្កបង្កើនផលដំណាំកសិកម្មតំបន់ជុំវិញបឹងទន្លេសាប | √ | √ | √ | 773,523,000 |
| | ២.៣.១. សិក្សាស្រាវជ្រាវចរន្តទីផ្សារកសិផល នៃសង្វាក់ដំណាំស្រូវវស្សា និងស្រូវប្រាំង | √ | √ | √ | 221,436,000 |
| | ២.៣.២. ចុះសិក្សា និងប្រមូលព័ត៌មានទិន្នន័យពីការបង្កបង្កើនផលស្រូវប្រាំង និងវស្សា | √ | √ | √ | 552,087,600 |
| | ២.៣.៣. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief) | √ | √ | √ | 30,000,000 |
| | ២.៤. សិក្សាស្រាវជ្រាវពីសង្វាក់អាជីវកម្មកែច្នៃធនធានជលផល | √ | √ | √ | 205,000,000 |
| | ២.៤.១. តាមដាន និងវាយតម្លៃពីសង្វាក់ផលិតកម្ម និងសិប្បកម្មកែច្នៃធនធានជលផល | √ | √ | √ | 190,000,000 |
| | ២.៤.២. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief) | √ | √ | √ | 15,000,000 |
| | ២.៥. សិក្សា និងវាយតម្លៃពីផលិតភាពធនធានជលផលនៅក្នុងបឹងទន្លេសាប | √ | √ | √ | 1597,200,000 |
| | ២.៥.១. តាមដាន និងវាយតម្លៃពីពីផលិតភាពធនធានជលផល នៅក្នុងបឹងទន្លេសាប | √ | √ | √ | 1590,200,000 |
| | ២.៥.២. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief) | √ | √ | √ | 7,000,000 |
| **នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ** | | √ | √ | √ | 6391,000,000 |
| **ទិសដៅទី ៣**<br><br>អភិបាលកិច្ចការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិក ក្នុងកិច្ចសហប្រតិបត្តិការ ដើម្បី | ៣.១. សម្របសម្រួល និងធ្វើឲ្យកាន់តែប្រសើរឡើងនូវដំណើរការគ្រប់គ្រងប្រព័ន្ធរដ្ឋបាលហិរញ្ញវត្ថុ និងបុគ្គលិក ក្នុងអង្គភាពអាជ្ញាធរទន្លេសាប | √ | √ | √ | 6287,000,000 |
| | ៣.១.១. បន្តពង្រឹងការគ្រប់គ្រងផ្នែករដ្ឋបាល | √ | √ | √ | 390,000,000 |
| | ៣.១.២. បង្កើនការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ | √ | √ | √ | 5100,000,000 |
| | ៣.១.៣. ជម្រុញប្រសិទ្ធភាពការគ្រប់គ្រងបុគ្គលិក-មន្ត្រីរាជការ | √ | √ | √ | 72,000,000 |
| | ៣.១.៤. បន្តការលើកកម្ពស់ការកសាងសមត្ថភាព | √ | √ | √ | 625,000,000 |

| | | | | | |
|---|---|---|---|---|---|
| លើកកម្ពស់ប្រសិទ្ធិភាពការងារសម្រាប់អាជ្ញាធរទន្លេសាប | ៣.១.៥. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief) | √ | √ | √ | 4,000,000 |
| | ៣.២. ពង្រឹងប្រសិទ្ធភាពដំណើរការអនុវត្តផែនការ និងកិច្ចសហប្រតិបត្តិការ | √ | √ | √ | 104,000,000 |
| | ៣.២.១. បន្តការយកចិត្តទុកដាក់នូវយន្តការរៀបចំផែនការ | √ | √ | √ | 30,000,000 |
| | ៣.២.២. គ្រប់គ្រងព័ត៌មាន ទិន្នន័យរបស់អាជ្ញាធរទន្លេសាប | √ | √ | √ | 50,000,000 |
| | ៣.២.៣. បន្តពង្រឹងកិច្ចសហប្រតិបត្តិការ | √ | √ | √ | 20,000,000 |
| | ៣.២.៤. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief) | √ | √ | √ | 4,000,000 |
| **នាយកដ្ឋានធនធានធម្មជាតិ** | | √ | √ | √ | 5,540,920,000 |
| **ទិសដៅទី ៤**<br>សម្របសម្រួល និងធ្វើឲ្យព័ត៌មាន ទិន្នន័យផ្នែកធនធានធម្មជាតិនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធកាន់តែប្រសើរឡើង | ៤.១. បច្ចុប្បន្នភាពព័ត៌មាន ទិន្នន័យសក្ដានុពលធនធានធម្មជាតិ តំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ | √ | √ | √ | 2,285,150,000 |
| | ៤.១.១. សិក្សាស្រាវជ្រាវពីប្រភេទព្រៃលិចទឹក និងរុក្ខជាតិផ្សេងៗតំបន់ជុំវិញបឹងទន្លេសាប | √ | √ | √ | 398,650,000 |
| | ៤.១.២. សិក្សាស្រាវជ្រាវពីសុខមាលភាពបឹងតាមតំបន់សំខាន់ៗនៅជុំវិញបឹងទន្លេសាប | √ | √ | √ | 414,750,000 |
| | ៤.១.៣. សិក្សាស្រាវជ្រាវពីគុណភាពដីកសិកម្មក្នុងតំបន់សំខាន់ៗជុំវិញបឹងទន្លេសាប | √ | √ | √ | 521,500,000 |
| | ៤.១.៤. សិក្សាស្រាវជ្រាវពីធនធានរ៉ែក្នុងតំបន់សំខាន់ជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ | √ | √ | √ | 304,500,000 |
| | ៤.១.៥. សិក្សាស្រាវជ្រាវពីជីវចម្រុះ តំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ | √ | √ | √ | 642,250,000 |
| | ៤.១.៦. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief) | √ | √ | √ | 3,500,000 |
| | ៤.២. សិក្សាស្រាវជ្រាវពីការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធអេកូឡូស៊ីជុំវិញបឹងទន្លេសាប | √ | √ | √ | 3,255,770,000 |
| | ៤.២.១.បច្ចុប្បន្នភាពព័ត៌មានទិន្នន័យប្រព័ន្ធស្រោចស្រពស្ទឹងសំខាន់ៗនិងអាងស្រែជុំវិញបឹងទន្លេសាប | √ | √ | √ | 2,115,960,000 |
| | ៤.២.២. សិក្សាស្រាវជ្រាវពីសក្ដានុពលសេដ្ឋកិច្ច លើការបង្កបង្កើនផលដំណាំចំការជុំវិញ តំបន់បឹងទន្លេសាប | √ | √ | √ | 1,134,560,000 |
| | ៤.២.៣. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief) | √ | √ | √ | 5,250,000 |

| | | | | | |
|---|---|---|---|---|---|
| **នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស** | | √ | √ | √ | 1133,000,000 |
| **ទិសដៅទី ៥** សម្របសម្រួល និងធ្វើឲ្យព័ត៌មាន ទិន្នន័យ នៃការធ្វើអាជីវកម្ម និងអភិរក្សធនធាននៅតំបន់បឹងទន្លេសាប និង តំបន់ពាក់ព័ន្ធកាន់ តែប្រសើរឡើងនូវការស្រង់ | ៥.១. ធ្វើបច្ចុប្បន្នភាពព័ត៌មានទិន្នន័យ ការធ្វើអាជីវកម្មធនធាន នៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ | √ | √ | √ | 951,000,000 |
| | ៥.១.១. សិក្សា និងវាយតម្លៃផលចាប់តាមឡូត៍ដាយ នៅរាជធានីភ្នំពេញ និងខេត្តកណ្ដាល ២០១៥-២០១៦ | √ | √ | √ | 305,000,000 |
| | ៥.១.២. សិក្សាពីសង្វាក់ការធ្វើអាជីវកម្មលើធនធានជីវចម្រុះ ជុំវិញបឹងទន្លេសាប | √ | √ | √ | 288,000,000 |
| | ៥.១.៣. តាមដានសង្វាក់ពាណិជ្ជកម្មច្រកចេញ-ចូលត្រី បណ្ដាខេត្តជុំវិញបឹងទន្លេសាប | √ | | | 98,000,000 |
| | ៥.១.៤. សិក្សាវាយតម្លៃធនធានជលផលតាមស្ទឹងសំខាន់ៗជុំវិញបឹងទន្លេសាប | √ | √ | √ | 228,000,000 |
| | ៥.១.៥. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief) | √ | √ | √ | 12,000,000 |
| | ៥.២. ធ្វើឲ្យប្រសើរឡើងនូវព័ត៌មាន ទិន្នន័យនៃការប្រើប្រាស់ឧបករណ៍នេសាទ និងតំបន់អភិរក្សធនធានជលផល ស្ថិតជុំវិញបឹងទន្លេសាប | √ | | | 182,000,000 |
| | ៥.២.១. ធ្វើបច្ចុប្បន្នភាពឧបករណ៍នេសាទនៅបណ្ដាខេត្តជុំវិញបឹងទន្លេសាប | √ | | | 76,000,000 |
| | ៥.២.២. ធ្វើបញ្ជីសារពើភ័ណ្ឌតំបន់អភិរក្សជលផល នៅតាមបណ្ដាខេត្តជុំវិញបឹងទន្លេសាប | √ | | | 102,000,000 |
| | ៥.២.៣. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief) | √ | | | 4,000,000 |
| **នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ** | | √ | √ | √ | 830,290,000 |
| **ទិសដៅទី ៦** ពង្រឹងប្រសិទ្ធភាពការអនុវត្តបទដ្ឋានគតិយុត្តិ និងធ្វើឲ្យប្រសើរឡើងនូវ | ៦.១. បន្តការចូលរួមលើកកម្ពស់ការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តិ ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ និងជីវចម្រុះតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ | √ | √ | √ | 381,300,000 |
| | ៦.១.១. ពង្រឹងការអនុវត្តបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការការពារតំបន់ជុំវិញបឹងទន្លេសាប | √ | √ | √ | 74,500,000 |
| | ៦.១.២. សិក្សាស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងកិច្ចការការពារធនធានធម្មជាតិ និងជីវចម្រុះ តំបន់បឹងទន្លេសាប | √ | √ | √ | 82,000,000 |

| | | | | | |
|---|---|---|---|---|---|
| ប្រព័ន្ធផ្សព្វផ្សាយ ក្នុងស្មារតីលើកកម្ពស់ដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ និងជីវចម្រុះ តំបន់បឹងទន្លេសាប និងតំបន់ពាក់ពន្ធ | ៦.១.៣. សិក្សាស្វែងយល់ពីការចែករំលែកអត្ថប្រយោជន៍ (Conflict Interest) រវាងអ្នកពាក់ព័ន្ធ ក្នុងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់បឹងទន្លេសាបប្រកបដោយនិរន្តរភាព | √ | √ | √ | 222,800,000 |
| | ៦.១.៤. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief) | √ | √ | √ | 2,000,000 |
| | ៦.២. បង្កើនការយល់ដឹងឲ្យបានទូលំទូលាយ សំដៅបម្រើឲ្យកិច្ចអភិរក្ស និងអភិវឌ្ឍន៍តំបន់ ទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព និងនិរន្តភាព | √ | √ | √ | 448,990,000 |
| | ៦.២.១. បច្ចុប្បន្នភាពប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានជាសាធារណៈ | √ | √ | √ | 330,990,000 |
| | ៦.២.២.បញ្ជ្រាបការយល់ដឹងជាសាធារណៈអំពីកិច្ចការពារធនធានធម្មជាតិ និងជីវចម្រុះបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ | √ | √ | √ | 118,000,000 |

# ផ្នែកទី ៤

# សកម្មភាពការងារប្រចាំឆ្នាំ ២០១៥ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

**១. សកម្មភាពអាទិភាពថ្នាក់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប**

**ទិសដៅការងារទី ១ ៖** បន្តការចូលរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការចាត់វិធានការ និងការការពារតំបន់ជុំវិញបឹងទន្លេសាបនិងតំបន់ពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព

**ផែនការសកម្មភាព ១.១.** អធិការកិច្ចព្រៃលិចទឹកតំបន់ 3 ជុំវិញបឹងទន្លេសាប

១.១.១. ចុះពិនិត្យ និងតាមដាន អំពីការបាត់បង់ព្រៃលិចទឹក

- ✓ ពិភាក្សា ពិនិត្យ និងស្រាវជ្រាវឯកសារគតិយុត្តិពាក់ព័ន្ធ
- ✓ រៀបចំផែនទី និងឯកសារពាក់ព័ន្ធ
- ✓ សម្របសម្រួល និងសហការជាមួយនឹងភាគីពាក់ព័ន្ធ
- ✓ ចុះសិក្សា និងប្រមូលព័ត៌មាន ទិន្នន័យ និងរូបភាពក្នុងទីតាំងជាក់ស្តែង
- ✓ រៀបចំចងក្រងឯកសាររបាយការណ៍ និងផែនទីពិសេសជូនថ្នាក់ដឹកនាំ និងរាជរដ្ឋាភិបាល

១.១.២. ចុះពិនិត្យ និងតាមដានបង្គោលកំណត់តំបន់ 3 ជុំវិញបឹងទន្លេសាប

- ✓ ពិនិត្យ និងស្រាវជ្រាវឯកសារគតិយុត្តិពាក់ព័ន្ធ
- ✓ រៀបចំផែនទី និងឯកសារពាក់ព័ន្ធ
- ✓ ចុះពិនិត្យ និងផ្ទៀងផ្ទាត់និយាមកាបង្គោលតំបន់ 3
- ✓ ប្រជុំពិភាក្សាកំណត់ការដាំបង្គោលបន្ថែម ការពារព្រៃលិចទឹកតំបន់ 3 ( សជណ 1044)
- ✓ សម្របសម្រួល និងសហការជាមួយនឹងភាគីពាក់ព័ន្ធ
- ✓ បោះបង្គោលបន្ថែម ការពារព្រៃលិចទឹកតំបន់ 3
- ✓ រៀបចំចងក្រងឯកសាររបាយការណ៍ និងផែនទីពិសេសជូនថ្នាក់ដឹកនាំ និងរាជរដ្ឋាភិបាល

១.១.៣. រៀបចំរបាយការណ៍/ខ្លឹមសារគោលនយោបាយ (Policy Brief)

**ផែនការសកម្មភាព ១.២.** សិក្សា និងវាយតម្លៃភាពអនាធិបតេយ្យ និងបទល្មើស ជុំវិញបឹងទន្លេសាប

១.២.១. ចុះពិនិត្យ និងតាមដានពីភាពស្ថានភាពអនាធិបតេយ្យ និងបទល្មើស

- ✓ ចុះពិនិត្យជាក់ស្តែងនៅតំបន់កើតមានភាពអនាធិបតេយ្យ និងបទល្មើស
- ✓ ចុះស្រង់ព័ត៌មានទូទៅពីអ្នកពាក់ព័ន្ធ អំពីការកើតនូវភាពអនាធិបតេយ្យ និងបទល្មើស
- ✓ វាយតម្លៃពីការកើនឡើង និងថយចុះនៃភាពអនាធិបតេយ្យ និងបទល្មើស
- ✓ រៀបចំរបាយការណ៍ និងផែនទីជូនថ្នាក់ដឹកនាំ និងរាជរដ្ឋាភិបាល

១.២.២. សម្របសម្រួល និងសហការក្នុងការទប់ស្កាត់ភាពអនាធិបតេយ្យ និងបទល្មើស

១.២.៣. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**ទិសដៅការងារទី ២ ៖** លើកកម្ពស់ប្រសិទ្ធិភាពការងារ និងសម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ

**ផែនការសកម្មភាព ២.១.** សិក្សា និងវាយតម្លៃអំពីតំបន់ដីសើមជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

២.១.១. សម្របសម្រួល ការប្រមូលចងក្រងព័ត៌មានទិន្នន័យតំបន់ដីសើមដែលមានស្រាប់

- ✓ ទំនាក់ទំនងជាមួយនឹងក្រសួង ស្ថាប័ន និងដៃគូរពាក់ព័ន្ធ ដើម្បីស្វែងយល់
- ✓ ពិនិត្យ និងប្រមូលចងក្រងឯកសារ បទដ្ឋានគតិយុត្តិ អំពីតំបន់ដីសើមជុំវិញបឹងទន្លេសាប

២.១.២. សិក្សាប្រមូលព័ត៌មាន ទិន្នន័យតំបន់ដីសើមជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

- ✓ ចុះសិក្សា និងស្រង់ស្ថិតិតំបន់ដីសើមជុំវិញវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ✓ ធ្វើបញ្ជីបច្ចុប្បន្នភាពតំបន់ដីសើមជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ✓ រៀបចំផែនទីកំណត់តំបន់ដីសើមជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

២.១.៣. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**ផែនការសកម្មភាព ២.២.** សិក្សា និងវាយតម្លៃពីការគ្រប់គ្រងកាកសំណល់ភូមិបណ្តែតទឹក ក្នុងតំបន់បឹងទន្លេសាប

២.២.១. សម្របសម្រួល និងធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យភូមិបណ្តែតទឹក ជាមួយនឹងអ្នកពាក់ព័ន្ធ

- ✓ សហការជាមួយក្រសួង ស្ថាប័ន និងដៃគូរ ដើម្បីស្វែងយល់ពីទីតាំងនៃភូមិបណ្តែតទឹក
- ✓ ចុះធ្វើបច្ចុប្បន្នភាពស្ថិតិ-ទិន្នន័យការរស់នៅភូមិបណ្តែតទឹក
- ✓ រៀបចំទិន្នន័យ និងផែនទីទីតាំងភូមិបណ្តែតទឹក

២.២.២. ចុះសិក្សា និងប្រមូលព័ត៌មាន ទិន្នន័យការប្រើប្រាស់កាកសំណល់រឹង និងរាវ

- ✓ សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងដៃគូរ ដើម្បីស្វែងយល់ពីកាកសំណល់រឹង និងរាវ
- ✓ ពិនិត្យ-ប្រមូលចងក្រងឯកសារ បទដ្ឋានគតិយុត្តិ អំពីការប្រើប្រាស់កាកសំណល់រឹង និងរាវ
- ✓ ស្រង់ព័ត៌មាន ទិន្នន័យការប្រើប្រាស់កាកសំណល់រឹង និងរាវជុំវិញបឹងទន្លេសាប

២.២.៣. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**ផែនការសកម្មភាព ២.៣.** សិក្សា និងវាយតម្លៃពីការបង្កបង្កើនផលដំណាំកសិកម្មតំបន់ជុំវិញបឹងទន្លេសាប

២.៣.១. សិក្សាស្រាវជ្រាវចរន្តទីផ្សារកសិផល នៃសង្វាក់ដំណាំស្រូវវស្សា និងស្រូវប្រាំង

- ✓ ទំនាក់ទំនង និងសហការជាមួយនឹងក្រសួង ស្ថាប័ន និងដៃគូរពាក់ព័ន្ធ ដើម្បីស្វែងយល់ពីចរន្តទីផ្សារកសិផល និងប្រមូលមូលដ្ឋានព័ត៌មាន ទិន្នន័យ ដែលមានស្រាប់
- ✓ ចុះស្រង់ព័ត៌មាន ទិន្នន័យទីតាំងជាក់ស្តែង នៃសង្វាក់ទីផ្សារកសិផល លើផលិតភាពដំណាំស្រូវ

២.៣.២. ចុះសិក្សា និងប្រមូលព័ត៌មានទិន្នន័យពីការបង្កបង្កើនផលស្រូវប្រាំង និងវស្សា

- ✓ ចុះសិក្សា និងប្រមូលព័ត៌មាន ទិន្នន័យស្រូវប្រាំង (ផ្ទៃដីដាំដុះ, ទិន្នផល និងវិធីសាស្ត្រ)
- ✓ ចុះសិក្សា និងប្រមូលព័ត៌មាន ទិន្នន័យស្រូវវស្សា (ផ្ទៃដីដាំដុះ, ទិន្នផល និងវិធីសាស្ត្រ)
- ✓ សិក្សា និងវិភាគប្រភេទដី និងបច្ចេកទេសនានា ក្នុងការបង្កបង្កើនដំណាំស្រូវ
- ✓ បច្ចុប្បន្នភាពព័ត៌មានទិន្នន័យបង្កបង្កើនផលស្រូវប្រាំង និងវស្សា (ផ្ទៃដីដាំដុះ និងទិន្នផល)
- ✓ រៀបចំផែនទីទីតាំងនៃការបង្កបង្កើនផលស្រូវប្រាំង និងវស្សាក្នុងតំបន់ 1, 2 និងតំបន់ 3

២.៣.៣. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**ផែនការសកម្មភាព ២.៤.** សិក្សាស្រាវជ្រាវពីសង្វាក់អាជីវកម្មកែច្នៃធនធានជលផល

២.៤.១. តាមដាន និងវាយតម្លៃពីសង្វាក់ផលិតកម្ម និងសិប្បកម្មកែច្នៃធនធានជលផល
- ✓ សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូរពាក់ព័ន្ធ ដើម្បីសិក្សាស្វែងយល់
- ✓ ពិនិត្យ និងបច្ចុប្បន្នភាពការស្រង់ព័ត៌មាន ទិន្នន័យ
- ✓ ចុះស្រង់ព័ត៌មាន ទិន្នន័យទីតាំងជាក់ស្តែង នៃសង្វាក់ផលិតកម្ម និងសិប្បកម្មកែច្នៃត្រីប្រហុកលក្ខណៈគ្រួសារតាមបណ្តោយបឹងទន្លេសាបតាមឡូត៍ដាយរាជធានីភ្នំពេញ និងខេត្តកណ្តាល
- ✓ ចុះស្រង់ព័ត៌មាន ទិន្នន័យទីតាំងជាក់ស្តែង នៃសង្វាក់ផលិតកម្ម សិប្បកម្មកែច្នៃត្រីប្រហុកប្រឡាក់លក្ខណៈ និងអាជីវកម្មតាមឡូត៍ដាយរាជធានីភ្នំពេញ និងខេត្តកណ្តាល
- ✓ សិក្សា និងវាយតម្លៃពីការកើនឡើង និងថយចុះបរិមាណធនធានជលផល
- ✓ វិភាគ និងរៀបចំរបាយការណ៍លំអិតពីការតាមដាន និងវាយតម្លៃពីសង្វាក់ផលិតកម្ម និងសិប្បកម្មកែច្នៃធនធានជលផល

២.៤.២. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**ផែនការសកម្មភាព ២.៥.** សិក្សាស្រាវជ្រាវពីផលិតភាពធនធានជលផលនៅក្នុងបឹងទន្លេសាប

២.៥.១. តាមដាន និងវាយតម្លៃពីផលិតភាពធនធានជលផលនៅក្នុងបឹងទន្លេសាប
- ✓ សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងដៃគូរ ដើម្បីស្វែងយល់ និងធ្វើបច្ចុប្បន្នភាពព័ត៌មាន ទិន្នន័យផលស្តុក
- ✓ ពិនិត្យ និងកែសម្រួលនិតិវិធី និងវិធីសាស្ត្រលើព័ត៌មាន ទិន្នន័យផលិតភាពធនធានជលផល
- ✓ ចុះសិក្សាពីផលិតភាពធនធានជលផល រួមមានទីជម្រក បរិមាណ ប្រភេទ និងទំហំត្រី នៅទីតាំងឃុំឆ្នុកទ្រូ ខេត្តកំពង់ឆ្នាំង និងឃុំផាត់សណ្តាយ ខេត្តកំពង់ធំ
- ✓ ចុះសិក្សាពីផលិតភាពធនធានជលផល រួមមានទីជម្រក បរិមាណ ប្រភេទ និងទំហំត្រីនៅតំបន់បឹងទន្លេឆ្មារ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ
- ✓ ចុះសិក្សាពីផលិតភាពធនធានជលផល រួមមានទីជម្រក បរិមាណ ប្រភេទ និងទំហំត្រីនៅទីតាំងឃុំកំពង់លួង ស្រុកក្រគរ ខេត្តពោធិ៍សាត់
- ✓ ចុះសិក្សាពីផលិតភាពធនធានជលផល រួមមានទីជម្រក បរិមាណ ប្រភេទ និងទំហំត្រីនៅតំបន់ព្រែកទាល់ ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង
- ✓ ចុះសិក្សាពីផលិតភាពធនធានជលផល រួមមានទីជម្រក បរិមាណ ប្រភេទ និងទំហំត្រីនៅឃុំកំពង់ភ្លុក និងអតីតឡូត៍នេសាទលេខ 4 ស្រុកសូត្រនិគម ខេត្តសៀមរាប
- ✓ វិភាគ និងចងក្រងរបាយការណ៍លំអិតពីផលិតភាពធនធានជលផលប្រចាំឆ្នាំ

២.៥.២. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

## ២. សកម្មភាពអាទិភាពថ្នាក់នាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

## ២.១. នាយដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ

**ទិសដៅការងារទី ៣ ៖** អភិបាលកិច្ចការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិក ក្នុងកិច្ចសហប្រតិបត្តិការ ដើម្បីលើកកម្ពស់ប្រសិទ្ធិភាពការងារសម្រាប់អាជ្ញាធរទន្លេសាប

**ផែនការសកម្មភាព ៣.១.** សម្របសម្រួល និងធ្វើឲ្យកាន់តែប្រសើរឡើងនូវដំណើរការគ្រប់គ្រងប្រព័ន្ធរដ្ឋបាល

ហិរញ្ញវត្ថុ និងបុគ្គលិក ក្នុងអង្គភាពអាជ្ញាធរទន្លេសាប

៣.១.១. បន្តពង្រឹងការគ្រប់គ្រងផ្នែករដ្ឋបាល

- ✓ សម្របសម្រួល និងផ្តល់សេវាកម្មទំនាក់ទំនងក្នុងដំណើរការរដ្ឋបាល
- ✓ ពិនិត្យ និងចាត់ចែងរបៀបរបបការងារក្នុងនាយកដ្ឋាននិងអង្គភាពទាំងមូល
- ✓ គ្រប់គ្រង និងចាត់ចែងរៀបចំរាល់លិខិត បទដ្ឋានគតិយុត្តិ និងឯកសារសម្ងាត់
- ✓ ចាត់ចែង និងរៀបចំកិច្ចប្រជុំនានារបស់អង្គភាពទាំងមូល
- ✓ គ្រប់គ្រង និងសម្របសម្រួលបណ្តាញទំនាក់ទំនង ទឹក ភ្លើង និងអនាម័យ
- ✓ បូកសរុបរបាយការណ៍នាយកដ្ឋាន និងអង្គភាពទាំងមូល

៣.១.២. បង្កើនការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ

- ✓ ពិនិត្យ និងរៀបចំគម្រោងផែនការថវិកាចំណាយប្រចាំឆ្នាំ
- ✓ ពិនិត្យ និងគ្រប់គ្រងបញ្ជីចំណូល-ចំណាយ
- ✓ ពិនិត្យ និងគ្រប់គ្រងចលនអចលនទ្រព្យ សន្និធិសម្ភារៈ- និងបញ្ជីសារពើភ័ណ្ឌ
- ✓ សម្របសម្រួល និងរៀបចំឯកសារលទ្ធកម្ម
- ✓ ផ្គត់ផ្គង់សម្ភារៈ និងបរិក្ខារក្នុងដំណើរការងារអង្គភាពទាំងមូល
- ✓ រៀបចំចងក្រងរបាយការណ៍គ្រប់គ្រងគណនេយ្យ និងហិរញ្ញវត្ថុ

៣.១.៣. ជម្រុញប្រសិទ្ធភាពការគ្រប់គ្រងបុគ្គលិក-មន្ត្រីរាជការ

- ✓ ពិនិត្យ និងរៀបចំគម្រោងផែនការបុគ្គលិកប្រចាំឆ្នាំ
- ✓ តាមដានពិនិត្យ និងបូកសរុបបញ្ជីវត្តមានមន្ត្រីរាជការ
- ✓ ពិនិត្យ និងវាយតម្លៃសមត្ថភាព និងការទទួលខុសត្រូវរបស់មន្ត្រីរាជការ
- ✓ សម្របសម្រួល និងរៀបចំឋានន្តរសក្តិ តួនាទីជូនមន្ត្រីរាជការ
- ✓ សម្របសម្រួល និងផ្តល់សេវាកម្មការងារជូនមន្ត្រីរាជការ
- ✓ បញ្ជ្រាបការយល់ដឹងផ្នែកយេនឌ័រក្នុងការគ្រប់គ្រងមន្ត្រីរាជការរបស់អាជ្ញាធរទន្លេសាប
- ✓ រៀបចំចងក្រងរបាយការណ៍គ្រប់គ្រងបុគ្គលិក

៣.១.៤. បន្តការលើកកម្ពស់ការកសាងសមត្ថភាព

- ✓ សម្របសម្រួល និងសហការជាមួយក្រសួង-ស្ថាប័ន និងដៃគូរពាក់ព័ន្ធ ដើម្បីលើកកម្ពស់កសាងសមត្ថភាពមន្ត្រីអ.ទ.ស
- ✓ បើកវគ្គបណ្តុះបណ្តាលស្តីអំពី ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ
- ✓ បើកវគ្គបណ្តុះបណ្តាលស្តីអំពី ការគ្រប់គ្រងព័ត៌មាន ទិន្នន័យ
- ✓ បើកវគ្គបណ្តុះបណ្តាលស្តីអំពី ការសិក្សាវាយតម្លៃផលចាប់ផលផល
- ✓ បើកវគ្គបណ្តុះបណ្តាលស្តីអំពី ការសិក្សាការវាយតម្លៃផលស្តុកជលផល
- ✓ បើកវគ្គបណ្តុះបណ្តាលស្តីអំពី ជីវសាស្ត្រត្រី និងជលវិទ្យា
- ✓ បើកវគ្គបណ្តុះបណ្តាលស្តីអំពី ការលូតលាស់ដំណាំកសិកម្ម និងវិធីសាស្ត្រប្រើប្រាស់ជី ពូជ
- ✓ បើកវគ្គបណ្តុះបណ្តាលស្តីអំពី វិធីសាស្ត្រស្រាវជ្រាវ

- ✓ បើកវគ្គបណ្តុះបណ្តាលស្តីអំពី ទស្សនៈទានសម្រាប់គម្រោង និងជំនាញសរសេររបាយការណ៍
- ✓ ចងក្រង និងរៀបចំរបាយការណ៍

៣.១.៥. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**ផែនការសកម្មភាព ៣.២.** ពង្រឹងប្រសិទ្ធភាពដំណើរការអនុវត្តផែនការ និងកិច្ចសហប្រតិបត្តិការ

៣.២.១. បន្តការយកចិត្តទុកដាក់នូវយន្តការរៀបចំផែនការ

- ✓ សម្របសម្រួល និងប្រមូលចងក្រងឯកសារពាក់ព័ន្ធ ដើម្បីសិក្សាស្វែងយល់
- ✓ រៀបចំសេចក្តីណែនាំ (Guideline) ដើម្បីកសាងផែនការថវិកាប្រចាំឆ្នាំ និងផែនការសកម្មភាពការងារ ដាក់ជូននាយកដ្ឋានជំនាញ
- ✓ តាមដាន និងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តផែនការថវិកាប្រចាំឆ្នាំ និងផែនការសកម្មភាពការងាររបស់ អ.ទ.ស
- ✓ បូកសរុប និងរៀបចំឯកសារផែនការប្រចាំឆ្នាំរបស់នាយកដ្ឋាន និងអ.ទ.ស
- ✓ បញ្ជ្រាបផែនការថវិកាប្រចាំឆ្នាំអ.ទ.ស ក្នុងផែនការប្រចាំឆ្នាំក្រសួងធនធានទឹក និងឧតុនិយម
- ✓ សម្របសម្រួល និងកសាងគម្រោងអាទិភាពរបស់ អ.ទ.ស ដើម្បីដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគសាធារណៈរបស់ក្រសួងធនធានទឹក និងឧតុនិយម
- ✓ រៀបចំចងក្រងរបាយការណ៍ដំណើរការការងារនៃវឌ្ឍនភាពកសាងផែនការ

៣.២.២. គ្រប់គ្រងព័ត៌មាន ទិន្នន័យរបស់អាជ្ញាធរទន្លេសាប

- ✓ បច្ចុប្បន្នភាពព័ត៌មាន ទិន្នន័យគម្រោង បាន និងកំពុងអនុវត្តជុំវិញបឹងទន្លេសាប
- ✓ សម្របសម្រួល និងបង្កើតកម្មវិធីគ្រប់គ្រងមូលដ្ឋានព័ត៌មានទិន្នន័យ (Database) សម្រាប់ អ.ទ.ស
- ✓ រៀបចំរបាយការណ៍ព័ត៌មាន ទិន្នន័យគម្រោង និងកម្មវិធីគ្រប់គ្រងទិន្នន័យ

៣.២.៣. បន្តពង្រឹងកិច្ចសហប្រតិបត្តិការ

- ✓ សម្របសម្រួល និងសហការជាមួយក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ ដើម្បីស្វែងយល់
- ✓ ទំនាក់ទំនង និងស្វែងរកការគាំទ្រទាំងថវិកា និងជំនួយបច្ចេកទេស ពីដៃគូអភិវឌ្ឍន៍នានា
- ✓ បន្តខិតខំពង្រឹងតួនាទី និងភារកិច្ចរបស់អ.ទ.ស ក្នុងកម្រិតថ្នាក់ជាតិ និងថ្នាក់តំបន់
- ✓ បន្តពង្រឹងភាពជាដៃគូរជាមួយគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដើម្បីបញ្ចូលគម្រោងអាទិភាព អ.ទ.ស ក្នុងកម្មវិធីអភិវឌ្ឍន៍អាងទន្លេ របស់គណៈកម្មការទន្លេមេគង្គ
- ✓ រៀបចំរបាយការណ៍កិច្ចសហប្រតិបត្តិការ

៣.២.៤. វិភាគ និងរៀបចំរបាយការណ៍/ខ្លឹមសារសង្ខេបគោលនយោបាយ (Policy Brief)

**២.២. នាយកដ្ឋានធនធានធម្មជាតិ**

**ទិសដៅការងារទី ៤ ៖** សម្របសម្រួល និងធ្វើឲ្យព័ត៌មាន ទិន្នន័យធនធានធម្មជាតិនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធកាន់តែប្រសើរឡើង

**ផែនការសកម្មភាព ៤.១.** បច្ចុប្បន្នភាពព័ត៌មាន ទិន្នន័យសក្តានុពលធនធានធម្មជាតិ តំបន់បឹងទន្លេសាបនិងតំបន់ពាក់ព័ន្ធ

៤.១.១. សិក្សាស្រាវជ្រាវពីប្រភេទព្រៃលិចទឹក និងរុក្ខជាតិផ្សេងៗតំបន់ជុំវិញបឹងទន្លេសាប

- ✓ សម្របសម្រួលជាមួយនឹងក្រសួង ស្ថាប័ន និងដៃគូរ ដើម្បីសិក្សាស្វែងយល់ និងធ្វើបច្ចុប្បន្ន ភាពប្រភេទព្រៃលិចទឹក និងរុក្ខជាតិផ្សេងៗ
- ✓ ចុះសិក្សាប្រភេទព្រៃលិចទឹកតំបន់ 2 និងតំបន់ 3 ខេត្តបាត់ដំបង និងបន្ទាយមានជ័យ
- ✓ ចុះសិក្សាប្រភេទព្រៃលិចទឹកតំបន់ 2 និងតំបន់ 3 ខេត្តសៀមរាប និងកំពង់ធំ
- ✓ ចុះសិក្សាប្រភេទព្រៃលិចទឹកតំបន់ ខេត្តកំពង់ចាម និងកណ្តាល
- ✓ ពិនិត្យ និងកែសម្រួលការស្រង់ព័ត៌មាន ទិន្នន័យនៃប្រភេទព្រៃលិចទឹកជុំវិញបឹងទន្លេសាប
- ✓ រៀបចំផែនទី និងរូបភាពបញ្ជីសារពើភ័ណ្ឌប្រភទព្រៃលិចទឹកជុំវិញបឹងទន្លេសាប
- ✓ វិភាគ និងចងក្រងរបាយការណ៍លំអិតពីប្រភេទផ្ទៃព្រៃលិចទឹកជុំវិញបឹងទន្លេសាប

៤.១.២. សិក្សាស្រាវជ្រាវពីសុខមាលភាពបឹង ស្ទឹងតាមតំបន់សំខាន់ៗនៅជុំវិញបឹងទន្លេសាប

- ✓ សម្របសម្រួលជាមួយក្រសួងស្ថាប័ន និងដៃគូរ ដើម្បីស្វែងយល់ព័ត៌មាន ទិន្នន័យ
- ✓ ចុះសិក្សា និងរៀបចំផែនទីពីរូបសាស្ត្រស្ថានភាពបឹង/ស្ទឹងសំខាន់ៗជុំវិញបឹងទន្លេសាប
- ✓ ចុះសិក្សា ស្រង់ព័ត៌មាន ទិន្នន័យពីរបបជលសាស្ត្របឹង/ស្ទឹងសំខាន់ៗជុំវិញបឹងទន្លេសាប
- ✓ ចុះប្រមូលយកសំណាកទឹក (ក្រោម/លើ) ក្នុងតំបន់សំខាន់ៗជុំវិញបឹងទន្លេសាប
- ✓ ពិសោធន៍សំណាកទឹក (គុណភាពទឹក និងផលប៉ះពាល់)
- ✓ វិភាគនិងចងក្រងរបាយការណ៍លំអិតពីសុខមាលភាពបឹង ស្ទឹង តាមតំបន់សំខាន់ៗនៅជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

៤.១.៣. សិក្សាស្រាវជ្រាវពីគុណភាពដីកសិកម្ម ក្នុងតំបន់សំខាន់ៗជុំវិញបឹងទន្លេសាប

- ✓ សម្របសម្រួលជាមួយនឹងក្រសួង ស្ថាប័ន និងដៃគូរ ដើម្បីសិក្សាស្វែងយល់ និងធ្វើបច្ចុប្បន្នភាពប្រភេទ និងផ្ទៃដីកសិកម្មជុំវិញបឹងទន្លេសាប/ទូទាំងប្រទេស
- ✓ ពិនិត្យ និងកែសម្រួលនិតិវិធី និងវិធីសាស្ត្រប្រមូលព័ត៌មាន ទិន្នន័យកសិកម្ម
- ✓ ចុះសិក្សា ស្រង់ព័ត៌មាន ទិន្នន័យពីប្រភេទ និងផ្ទៃដីកសិកម្មក្នុងតំបន់ 1, 2 និង 3 ខេត្តកំពង់ឆ្នាំង និងពោធិ៍សាត់
- ✓ ចុះសិក្សា ស្រង់ព័ត៌មាន ទិន្នន័យពីប្រភេទ និងផ្ទៃដីកសិកម្មក្នុងតំបន់ 1, 2 និង 3 ខេត្តបាត់ដំបង និងបន្ទាយមានជ័យ
- ✓ ចុះសិក្សា ស្រង់ព័ត៌មាន ទិន្នន័យពីប្រភេទ និងផ្ទៃដីកសិកម្មក្នុងតំបន់ 1, 2 និង 3 ខេត្តសៀមរាប និងកំពង់ធំ
- ✓ ចុះសិក្សា ស្រង់ព័ត៌មាន ទិន្នន័យពីប្រភេទ និងផ្ទៃដីកសិកម្មនៅតំបន់សំខាន់ៗក្នុងខេត្តកំពង់ចាម និងខេត្តកណ្តាល
- ✓ សិក្សា និងវិភាគប្រភេទដី និងបច្ចេកទេសនានា ក្នុងការបង្កបង្កើនផលដំណាំកសិកម្ម
- ✓ រៀបចំផែនទីតំបន់កសិកម្មជុំវិញបឹងទន្លេសាប
- ✓ វិភាគ និងចងក្រងរបាយការណ៍លំអិតពីគុណភាពដីកសិកម្ម ជុំវិញបឹងទន្លេសាប

